# កិច្ចការបញ្ចប់មេរៀនទី៨-ទឹកចិត្តដ៏ប្រពៃ

**អំណាន:** ចូរអានអត្ថបទខាងក្រោម រួចឆ្លើយនឹងសំណួរ ។

ថ្ងៃមួយស្រីនាថ បានត្រឡប់មកពីសាលារៀនមុនម៉ោង ។ មីងណានឆ្ងល់ក៏សួរ ៖ " យី ! ថ្ងៃនេះម្ដេចក៏កូនចេញពីរៀនមុនម៉ោងដូច្នេះ ? " ។ ស្រីនាថឆ្លើយ ៖ " ចាសម៉ាក់ ! ថ្ងៃនេះអ្នកគ្រូខ្ញុំឈឺ " ។ ស្រីនាថបានសុំម្ដាយឱ្យជូននាងទៅសួរសុខទុក្ខអ្នកគ្រូ ដែលកំពុងសម្រាកព្យាបាលនៅឯមណ្ឌលសុខភាព ។ មីងណានឆ្លើយ ៖ " អើ ! ល្អហើយកូន ម៉ាក់ជូនកូនទៅ តែចាំម៉ែរៀបចំផ្លែឈើបន្តិចផ្ញើជូនគាត់ " ។ ឃើញស្រីនាថ និងម្ដាយមកដល់ អ្នកគ្រូសប្បាយចិត្តខ្លាំងណាស់ ។ គាត់និយាយ ៖ " អ្នកគ្រូសូមអរគុណកូនស្រីនាថ និងអ្នកមីងដែលមកសួរទុក្ខខ្ញុំ " ។ មីងណានតប ៖ " មិនអីទេ ! សូមជូនពរអ្នកគ្រូឱ្យឆាប់ជាសះស្បើយ " ។ អ្នកគ្រូ ៖ " ចាស ! អរគុណ ! " ។

គូសសញ្ញា ✓ ក្នុងប្រអប់ ☐ ចម្លើយមួយដែលត្រឹមត្រូវ ។

១. ហេតុអ្វីបានជាស្រីនាថ ចេញពីរៀនមុនម៉ោង ?

☐ ក. សាលារៀនឈប់សម្រាក ☐ ខ. ស្រីនាថឈឺ

☐ គ. កង់ខូច ☐ ឃ. អ្នកគ្រូស្រីនាថឈឺ

២. តើស្រីនាថ និងម្ដាយនាំគ្នាទៅណា ?

☐ ក. ទៅសាលា ☐ ខ. ទៅផ្សារ

☐ គ. ទៅមណ្ឌលសុខភាព ☐ ឃ. ទៅមន្ទីរពេទ្យ

៣. តើស្រីនាថបានសុំម្ដាយឱ្យជូននាងទៅសួរសុខទុក្ខនរណា ?

☐ ក. អ្នកគ្រូ ☐ ខ. លោកគ្រូ

☐ គ. មីង ☐ ឃ. មិត្តរួមថ្នាក់

៤. តើម្ដាយស្រីនាថបានយកអ្វីជូនអ្នកជំងឺ ។

☐ ក. បបរ ☐ ខ. ផ្លែឈើ

☐ គ. ភេសជ្ជៈ ☐ ឃ. បាច់ផ្កា

៥. តើអត្ថបទខាងលើមានតួអង្គប៉ុន្មាននាក់ ?

☐ ក. មានពីរនាក់ ☐ ខ. មានបីនាក់

☐ គ. មានបួននាក់ ☐ ឃ. មានប្រាំនាក់

LIVEWORKSHEETS

# សំណេរ

១. ចូរពន្យល់ពាក្យខាងក្រោម ។

- មណ្ឌលសុខភាព ( )..........................................................................................។
- ប្រពៃ ( ) ...................................................................................................។
- សះស្បើយ ( ) ..............................................................................................។

២. ចូររៀនពាក្យ ឬកន្សោមពាក្យខាងក្រោមជាល្បះឱ្យបានត្រឹមត្រូវ ។

| | | | | | |
|---|---|---|---|---|---|
| យើង | ជា | របស់ | គ្រូបង្រៀន | ម្ដាយឪពុក | ទីពីរ |

..............................................................................................................................

| | | | | | |
|---|---|---|---|---|---|
| មាន | មណ្ឌលសុខភាព | ត្រូវទៅ | ពេល | ជំងឺ | យើង |

..............................................................................................................................

| | | | | | | |
|---|---|---|---|---|---|---|
| និង | មណ្ឌលសុខភាព | មីងណាន | នៅ | សុខទុក្ខ | ទៅសួរ | ស្រីនាថ |

..............................................................................................................................

៣. ចូរជ្រើសរើសពាក្យក្នុងប្រអប់ ទៅបំពេញល្បះខាងក្រោមរូបភាពឱ្យបានត្រូវ ។

| | | |
|---|---|---|
| មណ្ឌលសុខភាព | សំពះ | សុខ |










ក. កុមារីលើកដៃ....................។ ពេលជួបអ្នកគ្រូ ។

ខ. ស្រីនាថ និងម្ដាយទៅសួរ .......................អ្នកជំងឺ ។

គ. នេះជា................................ ក្នុងឃុំយើង ។

LIVEWORKSHEETS